កុំខឹងនឹងនរណា

ប្រទេសថៃ មិនអនុញ្ញាតឱ្យលោក សម រង្ស៊ី ប្រើទឹកដីថៃ សំរាប់ធ្វើសកម្មភាពនយោបាយប្រឆាំងនឹងរបបនៅភ្នំពេញ ដោយលើកយកគោលការណ៍ មិនជ្រៀតជ្រែក ចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសមួយ ដែលជាសមាជិក នៃ សមាគម នៃប្រទេសអាស៊ីភាគអគ្នេយ៍។ សេចក្ដីសម្រេចចិត្តបែបនេះ វាជាកិច្ចធម្មតា ព្រោះវាជាច្បាប់របស់សមាគមនេះ ហើយ សម រង្ស៊ី គួរគិតទុកជាមុន នៅក្នុងផែនការ នៃមាតុភូមិនិរត្តន៍របស់គាត់។ ដូច្នេះ នរអ្នកផង ដែលគាំទ្រ សម រង្ស៊ី កុំខឹងអ្វីនឹងរដ្ឋាភិបាលថៃ ហើយត្រូវគិតវិញថាបើ ថៃ គេធ្វើផ្ទុយពីច្បាប់ វាជា អំពើមួយគួរឱ្យបារម្ភទៅវិញទេ ដូចប្រទេសយៀកណាម តែងតែជ្រៀតជ្រែក ចូលកិច្ចការផ្ទៃក្នុងកម្ពុជា រហូតមកដល់សព្វថ្ងៃ។ ដូចយើងតែងតែរំឭកថា បើគ្មានការបះបោរអហិក្សាក្ដី ឬ ហិក្សាក្ដី ជាទ្រង់ទ្រាយធំរបស់ប្រជាពលរដ្ឋខ្មែរ ប្រឆាំងនឹងរបបនៅភ្នំពេញ វានឹងគ្មានព្រឹត្តិការណ៍ ថ្ងៃទី៩ វិច្ឆិកា ដូចដែល សម រង្ស៊ី បានគ្រងទុកនោះឡើយ, តែវាក៏មិនមែនជាជ័យជំនះរបស់របបនៅភ្នំពេញនោះដែរ ព្រោះរបបនេះ នៅតែប្រឈរមុខនឹងបញ្ហាអន្តរជាតិ ដែលខ្លួនកំពុងជួបប្រទះ ហើយបញ្ហា សម រង្ស៊ី វាច្បាស់ជានាំមក នូវទុក្ខបន្ថែមដល់ខ្លួន។ តែចំពោះលោក រង្ស៊ីវិញ បើគាត់គ្មានផែនការជំនួសនោះទេ ច្បាស់ជាគេទុកគាត់ជា នយ:ជន បន្ត្ធើនយោបាយផ្សងព្រេង, តែខ្មែរក៏មិនត្រូវខឹងនឹងនរជននេះដែរ ព្រោះវាជាបញ្ហារបស់ជាតិខ្មែរផ្ទាល់។

ឧប សៅ សុន្ធា **តំនិត** **៧ វិច្ឆិកា ២០១៩**